**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០១៧

**សេចក្ដីផ្ដើម** :

នៅក្នុងខែមីនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក ប្រជុំពេញអង្គចំនួន១លើក និងប្រជុំវិសាមញ្ញនីតិកាលទី៣ ព្រឹទ្ធសភាចំនួន១លើក ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ស្ដីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ នីតិកាលទី៣ និងពិនិត្យនិងឲ្យយោបល់លើសេចក្ដីស្នើច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ<br>- ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរដ្ឋសភា ដើម្បីពិនិត្យ និងសិក្សាលើសេចក្ដីស្នើច្បាប់ចំនួន១ច្បាប់ ។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្ដារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ និងប្រជុំវិសាមញ្ញនីតិកាលទី៣ ព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល បម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំចំនួន៧លើក មានអ្នកចូលរួមចំនួន៤៤៨នាក់<br>- ថតចម្លងឯកសារបានចំនួន១៦សំណើ អស់ក្រដាសចំនួន៣៩,៧២៨សន្លឹក<br>- ទូទាត់ថ្លៃទិញសម្ភារៈ ថ្លៃអាហារសម្រន់ ឧបត្ថម្ភមន្ត្រីបំពេញការងារលើសម៉ោង និងថ្លៃឈប់សម្រាកចំនួន១៥លើក<br>- បានធ្វើលិខិតបេសកកម្មជូនមន្ត្រីរាជការនៃ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២នាក់ ស្មើនឹង១ច្បាប់<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗចំនួន៦៧នាក់ និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន៦៥នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន១ច្បាប់ ពីរដ្ឋសភា និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជ-ក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន៣២ច្បាប់<br>- បន្តធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា និងបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងធ្វើជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន២ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន៥ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងបកប្រែកិច្ចការសភានៃសាធារណរដ្ឋហ្វីលីពីន<br>- បានរៀបចំទីកន្លែងប្រជុំចំនួន៣លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន១១លើក<br>- ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន១១លើក<br>- បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| វេចនាសម្ព័ន្ធនយោបាយ | វេចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរស្រុក ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការបែករំលែក និងផ្តល់ព័ត៌មានស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ នៅខេត្តព្រៃវែង<br>+ អញ្ជើញចុះសិក្សាស្រាវជ្រាវពីកត្តាសំខាន់ៗដែលជំរុញឲ្យមានការអភិវឌ្ឍរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលពាក់ព័ន្ធនឹងវិស័យដែលជាសមត្ថកិច្ច នៅខេត្តពោធិ៍សាត់ ប៉ៃលិន បន្ទាយមានជ័យ និងខេត្តបាត់ដំបង<br>+ អញ្ជើញចុះបេសកកម្មទៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ដើម្បីសិក្សាឈ្វេងយល់អំពីរបៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅថ្នាក់ឃុំ សង្កាត់ របៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្តោតលើមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង របៀបដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដីស្រុក ក្រុង របៀបដោះស្រាយទំនាស់ដែលថ្នាក់ស្រុកក្រុងបញ្ជូនមកថ្នាក់ខេត្ត និងការដោះស្រាយវិវាទផ្សេងៗ ការចូលរួមអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌ ការអនុវត្តច្បាប់ | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥១នាក់ ស្មើនឹង១២ច្បាប់<br>- ថត និងផ្សព្វផ្សាយព័ត៌មានសកម្មភាពរបស់សមាជិកព្រឹទ្ធសភា ចុះតាមដានការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកណ្តាល ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះចំនួន៨លើក<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមក្នុងវេទិកាផ្សេងៗ នៅតាមបណ្តាភូមិភាគឧបត្ថម្ភមន្ត្រីបំពេញការងារលើសម៉ោង និងថ្លៃឈប់សម្រាកចំនួន១៥លើក ព្រមទាំងបានទូទាត់ថ្លៃទិញសម្ភារៈ និងគ្រឿងអេឡិចត្រូនិកសរុបចំនួន៧លើក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្តាខេត្ត ក្រុងរាជធានីទាំង៨ភូមិភាគចំនួន២០នាក់ ស្មើនឹង២លើក ។ |

| | |
|---|---|
| ការងារផ្សព្វផ្សាយច្បាប់ និងការងារនីតិកម្ម សកម្មភាពការងាររបស់នគរបាលយុត្តិធម៌ ចំពោះការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងការពិនិត្យ និងទប់ស្កាត់ បង្ការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែ ក្នុងខេត្តក្រចេះ និងច្រកទ្វារត្រពាំងផ្លុង ក្នុងខេត្តត្បូងឃ្មុំ ការអនុវត្តក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីរបស់សាលាដំបូងខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ព្រមទាំងសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងកិច្ចការងារជាមួយសាលាដំបូងខេត្ត និងអយ្យការអមសាលាដំបូងខេត្តទាំងពីរ ។ | |

**៣.មុខងារតំណាង** :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់សម្តេចប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជូនព្រះរាជដំណើររបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ យាងចេញពីមាតុប្រទេសទៅកាន់សាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួម ក្នុងកិច្ចប្រជុំ និងជាអធិបតីក្នុងពិធីផ្សេងៗ សរុបចំនួន៣៣១លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនង ក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវ ប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ នៅខេត្តត្បូងឃ្មុំ |

| | |
|---|---|
| មានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>+ អនុញ្ញាតឲ្យលោកជំទាវ អ៊ីង កន្ថាផាវី និងគណៈប្រតិភូនារីចំនួន១៦៥នាក់ ចូលជួបសម្តែងការគួរសមក្នុងឱកាសអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព<br>+ អញ្ជើញជាអធិបតីក្នុងពិធីស្រោចស្រពសុគន្ធវារី ប្រគេនព្រះមេគុណខេត្តកំពង់ស្ពឺ និងមន្ត្រីសង្ឃ ក្រុង ស្រុកទាំង៨ នៃខេត្តកំពង់ស្ពឺ<br>+ អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធពិធីបូជាសព និងពិធីរាប់បាត្របុណ្យខួប៧ថ្ងៃ ជាមួយនឹង១០០ថ្ងៃ សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជធានីភ្នំពេញ<br>+ អញ្ជើញទៅពិនិត្យការដ្ឋានសាងសង់សាលារៀន និងជួបសំណេះសំណាល ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ លោកគ្រូ អ្នកគ្រូ លោកតា លោកយាយ ប្រជាពលរដ្ឋ និងសួរសុខទុក្ខពីជីវភាព និងការលក់ដូររបស់អាជីវករចំនួន២លើក នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល<br>+ អញ្ជើញជាអធិបតីក្នុងពិធីជប់លៀងជាកិត្តិយស ជូនគណៈប្រតិភូសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល នៃប្រទេសប៊ែលហ្ស៊ិក | រៀបចំវេទិកា និងកម្មវិធីផ្សេងៗ នៅខេត្តត្បូងឃ្មុំ កំពង់ចាម ពោធិ៍សាត់ បាត់ដំបង ក្រចេះ ប៉ៃលិន និងខេត្តបន្ទាយមានជ័យ<br>- បានអមដំណើរសមាជិកព្រឹទ្ធសភាចុះទៅបំពេញបេសកកម្ម នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ត្រពាំងថ្លុង នៅខេត្តត្បូងឃ្មុំ និងច្រកទ្វារព្រំដែនអន្តរជាតិ ត្រពាំងស្រែ នៅខេត្តក្រចេះ ព្រមទាំងរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូនក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តព្រះសីហនុ<br>- រៀបចំចាត់ចែងពិធីសំណេះសំណាលជាមួយមន្ត្រីរាជការជានារីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិនារី ៨មីនា លើកទី១០៦ ឆ្នាំ២០១៧<br>- បានសហការរៀបចំ និងចាត់ចែងពិធីគោរពវិញ្ញាណក្ខន្ធសពចំនួន១លើក<br>- បានចុះសួរសុខទុក្ខនិវត្តន៍ជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៧នាក់<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៥៤នាក់ ស្មើនឹង៤៥ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១១នាក់ ស្មើនឹង១១ច្បាប់<br>- ថតចម្លងឯកសារចំនួន១០សំណើ អស់ក្រដាសចំនួន៣,៣៧៣សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្តាខេត្ត ក្រុង |

| | |
|---|---|
| និងគណៈប្រតិភូសាធារណរដ្ឋឥណ្ឌូនេស៊ី ដែលបានអញ្ជើញមកចូលរួមគោរពវិញ្ញាណក្ខន្ធសពសម្តេចវិបុលបញ្ញា សុខ អាន ព្រមទាំងគណៈប្រតិភូព្រឹទ្ធសភាបារាំង នៅសណ្ឋាគារអ៊ិនធើខុនទីណង់តាល់ភ្នំពេញ ភោជនីយដ្ឋានតូប៉ាស់ និងភោជនីយដ្ឋានឡឺប្រេស៊ីដង់<br>+ អញ្ជើញទៅសួរសុខទុក្ខសម្តេចវិបុលបញ្ញា សុខ អាន ដែលសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន<br>+ អញ្ជើញជាអធិបតី និងថ្លែងសុន្ទរកថាបើកសិក្ខាសាលាស្តីពី បុណ្យទិវាភាសាបារាំង<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានជួបសំណេះសំណាល បើកកិច្ចប្រជុំ សិក្ខាសាលា សន្និសីទ និងធ្វើបទបង្ហាញពាក់ព័ន្ធនឹងមុខងារព្រឹទ្ធសភា ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗចំនួន២៥លើក<br>- បានទទួលពាក្យបណ្តឹងចំនួន៨ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន១៥ករណី ព្រមទាំងបានជូនដំណឹងទៅម្ចាស់បណ្តឹងអំពីចំណាត់ការចំនួន១៥នាក់<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេស ចំនួន១៩៨លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សា | រាជធានីទាំង៨ភូមិភាគចំនួន៣២៥នាក់ ស្មើនឹង២៧លើក<br>- ទទួលលិខិតចូលចំនួន១,០៤១ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១១៣ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុបចំនួន៧០លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗចំនួន១៥នាក់ ស្មើនឹង៣លើក<br>- ផ្តល់រូបថតចំនួន៣,៤៦០សន្លឹក និងអត្ថបទសារព័ត៌មានចំនួន៦០អត្ថបទ ជូនខុទ្ទកាល័យ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំប័ណ្ណជូនពរ និងសារជូនពរចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំ២០១៧<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៣៥នាក់ ធ្វើប័ណ្ណសមាជិកចំនួន៣៣នាក់ ខ្ចីសៀវភៅចំនួន៦១ក្បាល និងសងវិញចំនួន៤៨ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន១លើក របស់សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ និងថ្នាក់ដឹកនាំភូមិ នៅឃុំព្រៃទទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង មកកាន់ព្រឹទ្ធសភាចំនួន៤៨នាក់<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាព |

| | |
|---|---|
| ឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៣លើក ។ | ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៦៧ក្បាល ព្រឹត្តិបត្រចំនួន៣៥ច្បាប់ ទស្សនាវដ្ដីចំនួន៣៣ក្បាល និងកាសែតចំនួន១៨២ច្បាប់<br>- ថត និងផ្សព្វផ្សាយទស្សនាវដ្ដី និងព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន១៤១លើក ។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្ដេចប្រមុខរដ្ឋស្ដីទី និងថ្នាក់ដឹកនាំព្រឹទ្ធសភាបានអនុញ្ញាតឲ្យគណៈប្រតិភូបរទេស១៥រូប ប្រធានសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល (PFWB) នៃប្រទេសប៊ែលហ្ស៊ិក និងប្រធានក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា ចូលជួបជូនពរ សម្ដែងការគួរសម សវនាការ និងពិភាក្សាការងារ<br>- សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ ជួបពិភាក្សាការងារជាមួយគណៈប្រតិភូព្រឹទ្ធសភាបារាំង គណៈប្រតិភូសភាWB និងសមាជិកព្រឹទ្ធសភាបារាំង តំណាងប្រជាជនបារាំងនៅបរទេស<br>+ អនុញ្ញាតឲ្យឯកអគ្គរាជទូតថៃ ប្រចាំនៅ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- ធ្វើពិព័រណ៍រូបភាព ផ្ទាំងប៉ាណូ បដា ពាក្យស្លោក និងធ្វើហ្វុងអក្សរក្នុងពិធីផ្សេងៗចំនួន៧លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពគណៈប្រតិភូជាតិ អន្តរជាតិមកបំពេញទស្សនកិច្ចក្នុង និងក្រៅប្រទេសចំនួន២៩លើក<br>- រៀបចំសម្អាត តុបតែងសាល បម្រើ និងផ្ដល់សេវាផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន៦លើក ស្មើនឹង៧២នាក់<br>- ថតចម្លងឯកសារចំនួន២សំណើ អស់ក្រដាសចំនួន២៤២សន្លឹក |

| | |
|---|---|
| ព្រះរាជាណាចក្រកម្ពុជា អគ្គលេខាធិការអង្គការសម្ព័ន្ធភាពអាស៊ី ដើម្បីសិទ្ធិលំនៅដ្ឋាន(ACHR) ចូលជួបសម្តែងការគួរសម និងសវនាការ<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៣៦ នៅប្រទេសបង់ក្លាដេស ប្រជុំគណៈកម្មាធិការពិសេសស្តីពី ការបង្កើតសភាអាស៊ី (APA) នៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន និងប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើប្រាស់ភាសាបារាំង (APF) នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ។ | - ផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានីភ្នំពេញ និងទៅតាមបណ្តាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគ ចំនួន៥០នាក់ ស្មើនឹង៩លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី សុំទិដ្ឋាការ រៀបចំបែបបទបើកបន្ទប់ពិសេស (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូននិងទទួលដំណើរបេសកកម្មសរុបចំនួន១៧លើក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១១នាក់ ស្មើនឹង៥ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងឧបត្ថម្ភមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ថ្លៃចំណាយផ្សេងៗចំនួន៣០លើក<br>- រៀបចំបែបបទ និងនីតិវិធីសម្រាប់ដំណើរបេសកកម្មជូនសមាជិកព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន៣លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦៧នាក់ ស្មើនឹង៧លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង សភាវ៉ាល់ឡូនីព្រុចសែល ប៊ែលហ្ស៊ិក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |

| | |
|---|---|
| | សមាគមអគ្គលេខាធិការនិយាយភាសាបារាំង សង្គមស៊ីវិល ក្រសួង និងស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុងនិងក្រៅប្រទេស ស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល និងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - រៀបចំបែបបទសុំជំនួយពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី<br>- បានធ្វើបែបបទស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលថ្មី ព្រឹទ្ធសភា<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន។ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៨៨ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិកៈ<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៤០ច្បាប់<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការពិភាក្សា និងវាយតម្លៃស្ថានភាពបាត់បង់សម្បទាវិជ្ជាជីវៈរបស់លោក សេង ធីរិន<br>- ប្រជុំពិនិត្យ និងពិភាក្សាអំពីការស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងការត្រៀមគ្រឿងឥស្សរិយយសលើកទី២ ជូនសមាជិកព្រឹទ្ធសភា<br>- ប្រជុំអន្តរគណៈកម្មការ ដើម្បីពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តី |

| | |
|---|---|
| | សម្រេចស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការត្រួតពិនិត្យ និងរៀបចំបែបបទនីតិវិធី ដើម្បីធ្វើសមាហរណកម្ម ក្របខ័ណ្ឌបច្ចុប្បន្នទៅក្នុងក្របខ័ណ្ឌថ្មី<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស :<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និងក្រៅប្រទេសសរុបចំនួន៨វគ្គ មានសិក្ខាកាមចូលរួមចំនួន៩៥នាក់<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) បើកវគ្គភាសាអង់គ្លេសសម្រាប់មន្ត្រីសភា និងអនុវត្តកម្មវិធីកម្មសិក្សាពីនិស្សិតក្នុងប្រទេស និងក្រៅប្រទេស<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- ប្រជុំសិក្សាអំពីអង្គភាពថវិកាតាមកម្មវិធី និងសមិទ្ធកម្មកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ<br>- បន្តប្រជុំវាយតម្លៃលទ្ធកម្មសាធារណៈ<br>- ប្រជុំជាមួយក្រុមហ៊ុនធានារ៉ាប់រងសុខភាពសម្រាប់សមាជិក សមាជិកាព្រឹទ្ធសភា<br>- រៀបចំធ្វើរបាយការណ៍ចំណូល ចំណាយថវិកាព្រឹទ្ធសភាឆ្នាំ២០១៦ និងការបែងចែកថវិការបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០១៧<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិ |

| | |
|---|---|
| | ប្រចាំខែមីនាឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច ជួសជុលរថយន្ត និងសម្ភារៈឧបករណ៍បច្ចេកទេសផ្សេងៗ ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធ កែលម្អសោភ័ណ្ឌភាពក្នុងបរិវេណព្រឹទ្ធសភាចំនួន ៨០លើក<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន១១សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៤២សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាបម្រើភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ២៩លើក មានអ្នកចូលរួមចំនួន៦៤៩នាក់<br>- ផ្តល់សេវាថវិកាសម្រាប់ថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងទូទាត់ថ្លៃចំណាយផ្សេងៗ ចំនួន៨៤លើក<br>- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៥២សំណើ អស់ក្រដាសចំនួន ២០,៥២០សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនទៅតាមបណ្តាខេត្ត ក្រុងទាំង៨ភូមិភាគ និងក្នុងរាជធានីភ្នំពេញចំនួន១២៥នាក់ ស្មើនឹង៧២លើក<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់: |

| | |
|---|---|
| | - សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី អគារមូលនិធិ<br>- ជួសជុល និងរៀបចំបណ្តាញអគ្គិសនីនៅស្លាបខាងត្បូង ខាងស្តាំ ខាងកើត និងខាងលិចអគារក្រហម និងសង់បន្ទប់ទឹកបន្ថែមសម្រាប់សាលសិក្ខាសាលា បណ្ណាល័យ<br>- រៀបចំសុំគោលការណ៍ ដើម្បីត្រៀមរៀបចំជួសជុលអគារសាលប្រជុំពេញអង្គចាស់<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឲ្យមានសោភ័ណ្ឌភាពល្អ<br>- បិទផ្លាស្ទិចស្រអាប់ ខាត់ លាប ទ្វារកញ្ចក់ បង្អួច ដៃទ្វារទឹកមាស លាបស្នាមប្រឡាក់ នៅលើអគារក្រហមស្លាបខាងកើត សាលខាងជើង និងតាមកាំជណ្តើរនៅបណ្ណាល័យ<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច ប្តូរសោគុ ដៃទ្វារ តុកញ្ចក់ដាក់កេសជ្ជៈសរុបចំនួន១០៤គ្រឿង និងបណ្តាញទឹកចំនួន១២ខ្សែ<br>- បិទលេខកូដសម្ភារៈសារពើភ័ណ្ឌចំនួន១គ្រឿង<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន២៤គ្រឿង។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៥៦ចំណងជើង |

| | |
|---|---|
| | +ការងារផ្សេងៗ:<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន១២លើក<br>- បានរៀបចំ និងបញ្ចូលលេខកូដឯកសារសៀវភៅច្បាប់ សៀវភៅផ្សេងៗ និងចុះបញ្ជីឯកសារ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ជួសជុល និងផ្លាស់ប្តូរលេខកូដចាស់ៗសរុបចំនួន៣២៩ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម PMB E-Library បណ្តាញ Facebook សរុបចំនួន២,៨២២ក្បាល ។ |

**II.ទិសដៅការងារខែមេសា ឆ្នាំ២០១៧**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី១០

+សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាថ្មី ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនសម្តេចប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង (កម្មវិធីសម្ពោធសមិទ្ធផលវត្តចំនួន៣)

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ក្នុងនាមជាប្រធានព្រឹទ្ធសភា ឬជាប្រមុខរដ្ឋស្តីទីជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា ព្រមទាំងពិធីទទួលសារតាំងទូតថ្មី ( ទូត Croatia និងFinland)

+ត្រៀមការចុះហត្ថលេខារវាងលេខាធិការដ្ឋាន(APF) និងវិទ្យាស្ថានសភាកម្ពុជា (PIC) និងកម្មវិធីបណ្តុះបណ្តាលពីចំណាយរបស់លេខាធិកាដ្ឋាន(APF) ព្រមទាំងសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា (PIC) និង(IPU)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ ASGPF, SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO, JICA និង KOICA

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-បន្តបណ្តុះបណ្តាល PBO អ្នកស្រាវជ្រាវទូទៅ និងអ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ និងទំនាក់ទំនងលេខាធិការដ្ឋាន APF អំពីសហប្រតិបត្តិការបច្ចេកទេស បន្ទាប់ពីផលិតឯកសារ ៤ Modules

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ និងការអនុវត្ត MOU សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវសភា ឥណ្ឌា និងប៉ាគីស្ថាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

- បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់៖ ការជួសជុលដំបូល និងជញ្ជាំងអគារក្រហម ការជួសជុលផ្នែកស្ទាបស្ទាំអគារក្រហម សង់បន្ទប់ទឹកបន្ថែមសម្រាប់សាលសិក្ខាសាលាខាងត្បូង រៀបចំដូរកម្រាលព្រំនៅអគារក្រហមមាន បន្ទប់ទទួលភ្ញៀវ បន្ទប់រង់ចាំបន្ទប់គណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្ទប់ច្រកកាត់កណ្តាល ព្រមទាំងរៀបចំគូសគំនូសចំណតរថយន្ត និងសញ្ញាបង្ហាញផ្លូវ

-សិក្សាបង្វង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក

តាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំអន្តរគណៈកម្មការវិសោធនកម្មច្បាប់លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងលក្ខន្តិកៈសមាគមសង្គហៈសង្គ្រោះ

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំគណៈកម្មការរៀបចំធ្វើសមាហរណកម្មមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលក្នុងក្របខ័ណ្ឌថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជាជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រកពពីកូរ៉េ ជប៉ុន ចិន អូស្រ្តាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី ថៃ និងប្រទេសផ្សេងៗទៀត

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ត្រៀមអបអរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកាតាមកម្មវិធីជាក់ស្តែងក្នុងត្រីមាសទី២ ឆ្នាំ២០១៧

-រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៧ បច្ចុប្បន្នភាពផែនការយុទ្ធសាស្រ្ត១០ឆ្នាំ រៀបចំគម្រោងថវិកាសម្រាប់ឆ្នាំ២០១៨។

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែមីនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មដោយបានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១លើក ប្រជុំពេញអង្គចំនួន១លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន១លើក និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានដោយរលូន ។ ចំពោះមុខងារតាមដានការអនុវត្តច្បាប់ បានចុះសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មាននៅខេត្តព្រៃវែង ។

ដោយឡែកលើមុខងារតំណាង បានជួបសំណេះសំណាលជាមួយគណៈប្រតិភូនារី ក្រសួងកិច្ចការនារី និងប្រជាពលរដ្ឋ ព្រមទាំងពិធីស្រោចស្រព សុគន្ធវារី ប្រគេនព្រះមុនីសត្ថាចារ្យកោសល កែវ ចន្ទា ព្រះមេគុណខេត្ត និងគោរពវិញ្ញាណក្ខន្ធសពសម្តេចវិបុលបញ្ញា សុខ អាន រួមទាំងពិធីផ្សេងៗទៀត នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ធំ កំពង់ចាម ក្រចេះ បាត់ដំបង និងខេត្តបន្ទាយមានជ័យ។ ការអភិវឌ្ឍស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានឆ្លុះបញ្ចាំងឲ្យឃើញនៅសូចនាករវិជ្ជមាននៃការកៀរគរដៃគូឧបត្ថម្ភគាំទ្រជំនួយពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ សំដៅអភិវឌ្ឍន៍ធនធានមធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែសម្បូរបែប ទំនើប និងទាន់ការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា រួមទាំងការរីកចម្រើនក្នុងតំបន់ និងពិភពលោក ។ ការរៀបចំទិវាហ្វ្រង់កូហ្វូនី បានដើរទន្ទឹមនឹងការធ្វើបដិសណ្ឋារកិច្ចគណៈប្រតិភូមកពីព្រឹទ្ធសភាបារាំង និងសភា WB ដែលបានប្រព្រឹត្តទៅដោយរលូន និងបានចុះអនុស្សារណៈលើកិច្ចសហប្រតិបត្តិការអន្តរសភាជាមួយសភា WB ព្រមទាំងកម្មវិធីសហប្រតិបត្តិការជាមួយសមាគមបេសកកម្មអាស៊ី (បញ្ជូនមន្ត្រីទស្សនកិច្ចសិក្សា និងទទួលអ្នកជំនាញមកបង្រៀន ដើម្បីផ្លាស់ប្តូរបទពិសោធន៍ឆ្នាំ២០១៧) ។

ភ្នំពេញ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧

**អគ្គលេខាធិការស្តីទី**

ឡោក ឆាយ